# ឧបសម្ព័ន្ធ

## ក) បទដ្ឋានច្បាប់អន្តរជាតិ៖

### អនុសញ្ញាប្រឆាំងទារុណកម្ម (CAT)

**មាត្រា ២ កថាខ័ណ្ឌទី ២៖**

.....

២. ទោះក្នុងករណីប្រទេសមានសង្គ្រាម ឬត្រូវរងគំរាមដោយសង្គ្រាម ទោះមានអស្ថិរភាពនយោបាយក្នុងស្រុក ឬមានភាពអាសន្នសាធារណៈបែបណាក៏ដោយ ក៏គ្មានកាលៈទេសៈពិសេសណាមួយ អាចយកជាលេសដើម្បីធ្វើឱ្យ "ទារុណកម្ម" ក្លាយជាអំពើស្របច្បាប់ឡើយ ។

.....

### អនុសញ្ញាស្តីពីការបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW)

**មាត្រា ១៤ កថាខ័ណ្ឌទី ២៖**

.....

២. រដ្ឋជាភាគីទាំងឡាយ នឹងប្រកាន់យកនូវវិធានការសមស្របនានា ដើម្បីបំបាត់ការរើសអើងប្រឆាំងនារីភេទនៅជនបទ ដើម្បីឱ្យអ្នកទាំងនោះអាចចូលរួមនឹងទទួលបាននូវអត្ថប្រយោជន៍ពីកិច្ចអភិវឌ្ឍន៍ជនបទ ដោយឈរលើមូលដ្ឋាននៃសមភាពរវាងបុរស និងនារី ហើយជាពិសេសត្រូវធានាជូននារីជនបទ ទាំងនោះនូវសិទ្ធិ៖

ក- ចូលរួមក្នុងការតាក់តែង និងអនុវត្តនូវផែនការអភិវឌ្ឍនៅគ្រប់ថ្នាក់ ។

ខ- អាចទទួលបាននូវរាល់កិច្ចឧបត្ថម្ភផ្នែកសុខាភិបាល រួមទាំងការទទួលព័ត៌មាន ការជូនមតិ និងសេវានានានៅក្នុងផែនការគ្រួសារថែមទៀតផង ។

គ- ទទួលបានដោយផ្ទាល់នូវអត្ថប្រយោជន៍ពីកម្មវិធីសន្តិសុខសង្គម ។

ឃ- ទទួលបាននូវការបណ្តុះបណ្តាល និងអប់រំគ្រប់ប្រភេទ ទាំងរៀបរយ និងទាំងមិនរៀបរយ រួមបញ្ចូលទាំងការងារទាក់ទិននឹងអក្ខរកម្ម វិជ្ជាជីវៈ និងក្រៅពីនេះ ការទទួលបាននូវអត្ថប្រយោជន៍ពីសហគមន៍ ហើយនិងសេវាដែលមានទាំងប៉ុន្មាន ដើម្បីបង្កើនសមត្ថកិច្ចតិចនិចរបស់ខ្លួន ។

ង- ចាត់តាំងក្រុមជួយខ្លួនដោយខ្លួនឯង ហើយនិងសហករណ៍ ដើម្បីទទួលបាននូវផលប្រយោជន៍សេដ្ឋកិច្ចស្មើគ្នាតាមរយៈការបំពេញការងារ ឬស្វ័យបំពេញការងារ ។

ច- ចូលរួមក្នុងរាល់សកម្មភាពរបស់សហគមន៍ ។

ឆ- ទទួលបាននូវឥណទាន និងការខ្ចីលុយផ្នែកកសិកម្ម ការជួយសំរួលក្នុងការរកទីផ្សារ តិចណូឡូស៊ី សមស្រប ហើយនិងទទួលនូវស្ថានភាពស្មើភាពនៅក្នុងការកែទំរង់ដីធ្លី និងកសិកម្ម ក៏ដូចជានៅក្នុងគំរោងបែងចែកដីធ្លីផងដែរ ។

ជ- ទទួលបាននូវស្ថានភាពរស់នៅមួយដ៏សមរម្យ ជាពិសេសក្នុងចំណុចទាក់ទិនដល់បញ្ហាផ្ទះសំបែង អនាម័យ ការផ្គត់ផ្គង់ទឹក និងអគ្គិសនី ការដឹកជញ្ជូន និងទាក់ទងព័ត៌មាន ។

## អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)

### មាត្រា ១៥ កថាខ័ណ្ឌទី ១:

១- រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងសេរីភាពចូលរួមជាមួយសមាគម និងសេរីភាពធ្វើការជួបជុំដោយសន្តិវិធី ។

.....

## អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់ចោលសព្វបែបយ៉ាងនៃការប្រកាន់ពូជសាសន៍ (CERD)

### មាត្រា៤ ចំនុច (ខ):

រដ្ឋជាភាគីទាំងឡាយផ្តន្ទាទោសដល់ការឃោសនា និងដល់អង្គការទាំងឡាយណាដែលជាឫសគល់នៃគំនិត ឬទ្រឹស្តីនៃឧត្តមភាពរបស់ពូជសាសន៍មួយ ឬមនុស្សមួយក្រុមដែលមានពណ៌សំបុរតែមួយ ឬដែលមានជាតិកំណើតដើមតែមួយ ឬដែលខំប្រឹងធ្វើឱ្យសមហេតុផល ឬខំជំរុញឱ្យមានការស្អប់ខ្ពើម និងការរើសអើងពូជសាសន៍ ទោះក្នុងទំរង់ណាក៏ដោយ ហើយសន្យាថានឹងប្រកាន់យកវិធានការជាបន្ទាន់ និងជាវិជ្ជមាន ដើម្បីកំចាត់ចោលឱ្យអស់នូវការប្រព្រឹត្ត ឬការញុះញង់ឱ្យមានការរើសអើងពូជសាសន៍នានា ហើយក្នុងទិសដៅនេះ ដោយយោងទៅលើគោល-ការណ៍ទាំងឡាយ ដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ហើយនិងសិទ្ធិដែលបានចែងយ៉ាងច្បាស់នៅក្នុងមាត្រា៥ នៃអនុសញ្ញានេះ ក្នុងចំណោមប្រការទាំងនោះមាន:

.....

(ខ) ត្រូវប្រកាសថាជាការខុសច្បាប់ ហើយត្រូវហាមឃាត់រាល់អង្គការ និងរាល់សកម្មភាពរៀបចំ ព្រមទាំងសកម្មភាពឃោសនាផ្សេងៗទៀតដែលជំរុញ និងញុះញង់ឱ្យមានការរើសអើងពូជសាសន៍ ហើយត្រូវចាត់ទុកថាការចូលរួមក្នុងអង្គការ ឬសកម្មភាពបែបនេះ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ ។

.....

## សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស (UDHR)

### បុព្វកថា

ដោយយល់ឃើញថា ការទទួលស្គាល់នូវសេចក្តីថ្លៃថ្នូររបស់មនុស្សដែលមានតាំងពីកំណើត និងសិទ្ធិស្មើភាពគ្នា និងដែលមិនអាចដកហូតបានរបស់ពូជពង្សមនុស្សគ្រប់រូប គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

ដោយយល់ឃើញថា ការមិនទទួលស្គាល់ និងការប្រមាថមើលងាយសិទ្ធិមនុស្ស បាននាំឱ្យកើតមាននូវអំពើព្រៃផ្សៃសាហាវយង់ឃ្នង ដែលជាទំនាស់យ៉ាងខ្លាំងដល់មនសិការមនុស្សជាតិ និងដោយហេតុថា មនុស្សដែលមានជីវិតរស់នៅក្នុងពិភពលោក ត្រូវមាននូវសេរីភាពក្នុងការនិយាយស្តី ជំនឿ និង សេរីភាពផុតពីអំពើភេរវកម្ម និងភាពក្រីក្រតោកយ៉ាក ត្រូវបានប្រកាសថា ជាសេចក្តីប្រាថ្នាដ៏ឧត្តមបំផុតរបស់មនុស្សទូទៅ ។

ដោយយល់ឃើញថា ជាការចាំបាច់ដែលថា សិទ្ធិមនុស្សត្រូវតែមាននូវកិច្ចការពារដោយធម្មាធិបតេយ្យ ប្រសិនបើ មនុស្សមិនត្រូវបានទទួលរងនូវការបង្ខិតបង្ខំ ឱ្យចាប់យកនូវគ្រឿងដោះបន្ទាល់ ជាជំរើសចុងក្រោយ ដើម្បីបះបោរប្រឆាំងនឹងអំណាចផ្តាច់ការ និងការគៀបសង្កត់ទេនោះ ។

ដោយយល់ឃើញថា ជាការចាំបាច់ណាស់ដើម្បីលើកស្ទួយដល់ការពង្រីកនូវទំនាក់ទំនងជាមិត្តភាព រវាងប្រជាជាតិនានា ។

ដោយយល់ឃើញថា នៅក្នុងធម្មនុញ្ញ ប្រជាពលរដ្ឋទាំងអស់នៃសហប្រជាជាតិ បានប្រកាសសារជាថ្មីម្តងទៀត នូវជំនឿរបស់ខ្លួនទៅលើសិទ្ធិសំខាន់ៗ សេចក្តីថ្លៃថ្នូរ តម្លៃមនុស្ស និងលើសិទ្ធិស្មើគ្នា រវាងបុរស និងស្ត្រី ហើយប្រជាពលរដ្ឋទាំងអស់នៃសហប្រជាជាតិបានប្រកាសយ៉ាងប្តូរផ្តាច់ ដើម្បីលើកស្ទួយ វឌ្ឍនភាពសង្គម និងបទដ្ឋានដ៏ប្រសើរ នៃការរស់នៅក្នុងសេរីភាពដ៏ទូលំទូលាយ ។

ដោយហេតុថា ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ រដ្ឋជាសមាជិកទាំងអស់ បានសច្ចាធ្វើឱ្យបានសំរេចនូវការលើកស្ទួយការគោរពជាសកល ចំពោះសិទ្ធិមនុស្ស និងការប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាពសំខាន់ៗទាំងឡាយ ។

ដោយយល់ស្របថា ការយល់ដឹងជាទូទៅនូវសិទ្ធិ និងសេរីភាពទាំងនេះ មានសារសំខាន់ដ៏ធំធេងបំផុត ដើម្បីធ្វើឱ្យបានទទួលយ៉ាងពេញលេញ នូវការសច្ចាប្រណិធាននេះ

## ដោយហេតុនេះ នៅពេលនេះ មហាសន្និបាតប្រកាសថា៖
## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

គឺជាបទដ្ឋាន នៃសេចក្តីសំរេចបានរួមគ្នាមួយ សំរាប់ប្រជាពលរដ្ឋ និងប្រជាជាតិទាំងអស់ ទៅកាន់ទីបញ្ចប់មួយត្រង់ថា បុគ្គលគ្រប់ៗរូប និងអង្គការសង្គមទាំងអស់ ដែលរក្សាជាប់ក្នុងចិត្តជានិច្ចនូវសេចក្តីប្រកាសនេះ ត្រូវខិតខំប្រឹងប្រែងតាមរយៈការបង្រៀន និងអប់រំដើម្បីលើកស្ទួយការគោរពសិទ្ធិ និងសេរីភាពទាំងនេះ និងតាមរយៈវិធានការជាតិ និងអន្តរជាតិជាលំដាប់ៗទៅមុខ ដើម្បីធានាឱ្យបាននូវការទទួលស្គាល់ និងការប្រតិបត្តិតាមជាសកល និងប្រកបដោយប្រសិទ្ធិភាព ទាំងក្នុងចំណោមប្រជាពលរដ្ឋនានា នៃរដ្ឋជាសមាជិកខ្លួនឯង ទាំងក្នុងចំណោមប្រជាពលរដ្ឋនានា ដែលរស់នៅក្រោមដែនអំណាចច្បាប់របស់ខ្លួន ។

**មាត្រា ១៖**

មនុស្សទាំងអស់កើតមកមានសេរីភាព និងភាពស្មើៗគ្នាក្នុងសិទ្ធិ និងសេចក្តីថ្លៃថ្នូរ ។ មនុស្សគ្រប់រូបសុទ្ធតែមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈ ហើយត្រូវប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក ក្នុងស្មារតីរាប់អានគ្នាជាបងប្អូន ។

**មាត្រា ២:**

មនុស្សគ្រប់រូបមានសិទ្ធិ និងសេរីភាពគ្រប់បែបយ៉ាងទាំងអស់ ដែលមានចែងក្នុងសេចក្តីប្រកាសនេះដោយគ្មានការបែងចែកជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ប្រភពជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬឋានៈដទៃៗទៀតឡើយ ។

បន្ថែមលើនេះទៀត មិនត្រូវធ្វើការបែងចែកណាមួយ ដោយសំអាងទៅលើឋានៈខាងនយោបាយ ខាងដែនសមត្ថកិច្ច ឬឋានៈជាអន្តរជាតិ នៃប្រទេស ឬដែនដី ដែលបុគ្គលមួយរូបជាសមាជិកឡើយ ទោះប្រទេសនោះជាប្រទេសឯករាជ្យ ឬស្ថិតនៅក្រោមអាណត្តិគ្រប់គ្រង ឬមិនគ្រប់គ្រងដោយខ្លួនឯង ឬស្ថិតក្រោមការដាក់កំរិតដទៃៗណាមួយ នៃអធិបតេយ្យភាពយ៉ាងណាក៏ដោយ ។

**មាត្រា ៣:**

បុគ្គលម្នាក់ៗ ត្រូវមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

**មាត្រា ២៣:**

១- មនុស្សគ្រប់រូប មានសិទ្ធិធ្វើការងារ មានសិទ្ធិជ្រើសរើសការងារ និងមានសិទ្ធិធ្វើការងារ ក្នុងលក្ខណៈត្រឹមត្រូវ និងគួរពេញចិត្ត ព្រមទាំងមានសិទ្ធិទទួលបាននូវកិច្ចការពារទល់នឹងភាពឥតមានការងារធ្វើ ។
២- មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សរ៍ស្មើគ្នា សំរាប់ទង្វើការងារដូចគ្នា ដោយឥតមានការរើសអើងអ្វីឡើយ ។
៣- ជនដែលធ្វើការងារ មានសិទ្ធិទទួលបាននូវប្រាក់បំណាច់ត្រឹមត្រូវ និងគួរពេញចិត្ត ដើម្បីធានាជីវភាពរស់នៅរបស់គេ និងគ្រួសារគេ ឱ្យមាននូវតម្លៃ នៃសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយត្រូវបានបំពេញបន្ថែម តាមមធ្យោបាយការពារផ្នែកសង្គមផ្សេងៗទៀត ប្រសិនបើមានការចាំបាច់ ។
៤- មនុស្សគ្រប់រូប មានសិទ្ធិបង្កើតសហជីព និងមានសិទ្ធិចូលជាសមាជិក នៃសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

**មាត្រា ២៩:**

១- បុគ្គលម្នាក់ៗមានករណីយកិច្ចចំពោះសហគមន៍ ដែលជាកន្លែងតែមួយគត់ ដែលអាចបង្កើតនូវការរីកចំរើនពេញបរិបូរណ៍ និងដោយសេរី នូវបុគ្គលិកលក្ខណៈរបស់ខ្លួន។

២- ក្នុងការអនុវត្តន៏សិទ្ធិសេរីភាពរបស់ខ្លួន មនុស្សគ្រប់រូប ត្រូវស្ថិតក្នុងការកំណត់ទាំងឡាយណាដែលច្បាប់បានកំណត់ក្នុងគោលបំណងឱ្យមានការទទួលស្គាល់ និងគោរពដល់សិទ្ធិ និងសេរីភាពទាំងឡាយរបស់អ្នកដទៃ និងដើម្បីឆ្លើយតបនឹងការតម្រូវយ៉ាងត្រឹមត្រូវអំពីសីលធម៌ របៀបរៀបរយសាធារណៈ និងនៃសុខុមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យតែប៉ុណ្ណោះ ។
៣- ក្នុងករណីណាក៏ដោយ សិទ្ធិ និងសេរីភាពទាំងនោះ មិនអាចយកទៅប្រើប្រាស់ផ្ទុយនឹងគោលការណ៏ របស់សហប្រជាជាតិឡើយ។

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)

### មាត្រា ១៧ កថាខ័ណ្ឌទី ១:

១- មនុស្សគ្រប់រូប មានសិទ្ធិការពារខ្លួនកុំឱ្យមានការវាយប្រហារទៅលើកិត្តិយស កិត្តិនាមខ្លួនតាមតែអំពើចិត្ត ឬដោយប្រាសចាកពីគន្លងច្បាប់ ។ រីឯការរំខានដល់គេហដ្ឋាន ក្រុមញាតិ មិត្តភ័ក្តិ ព្រមទាំង រឿងរ៉ាវផ្ទៃក្នុងរបស់បុគ្គលម្នាក់ៗ ដោយពុំស្របតាមច្បាប់ក៏ត្រូវហាមឃាត់ដែរ ។
......

### មាត្រា ១៨:

១- ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការប្រើគំនិតគិតគូរ សតិសម្បជញ្ញៈ និងជំនឿសាសនា ។ សិទ្ធិនេះ ត្រូវរាប់ទាំងសេរីភាពក្នុងការកាន់ និងគោរពសាសនា ឬជំនឿណាមួយ នៃជំរើសរបស់ខ្លួន និងសេរីភាព ក្នុងការសម្តែងនូវការគោរពសាសនា ឬជំនឿក្នុងពិធីធ្វើសក្ការៈបូជាព្រះកាយ ប្រតិបត្តិតាមការអនុវត្តន៏ និងការបង្ហាត់បង្រៀនជាបុគ្គល ឬជាសហគមន៏ជាមួយអ្នកដទៃ និងជាសាធារណៈ ឬជាឯកជន ។
២- គ្មានជនណាម្នាក់ត្រូវគេបង្ខិតបង្ខំឱ្យកាន់ ឬគោរពសាសនា ឬជំនឿបែបណាមួយដែលប្រាសចាកពីការជ្រើស-រើសដោយសេរីរបស់ខ្លួនឡើយ ។
៣- សេរីភាពក្នុងការសម្តែងនូវការគោរពសាសនា ឬជំនឿផ្សេងៗរបស់ជនណាម្នាក់ អាចតម្រូវទៅនឹងការដាក់កំហិតព្រំដែនខ្លះៗ ដែលមាននៅក្នុងច្បាប់ និងជាការចាំបាច់ដើម្បីការពារសុវត្ថិភាព, សណ្តាប់ធ្នាប់ សុខុមាលភាព ឬសីលធម៌សាធារណៈ ឬក៏ដើម្បីការពារនូវសិទ្ធិ និងសេរីភាពជាមូលដ្ឋាន របស់អ្នកដទៃតែប៉ុណ្ណោះ ។
៤- រដ្ឋដែលភាគីទៅនឹងកតិកាសញ្ញាបច្ចុប្បន្ន ត្រូវគោរពដល់សេរីភាពនៃមាតាបិតា និងអ្នកអាណាព្យាបាលស្របច្បាប់ទាំងឡាយ ដើម្បីធានាដល់ការអប់រំខាងវិស័យសាសនា និងសីលធម៌នៃបុត្រធីតារបស់គេឱ្យបានសមស្របទៅតាមជំនឿរបស់ពួកគេ ។

### មាត្រា ១៩:

១- ជនគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក "ដោយសេរី" ។
២- ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញយោបល់ ។ សិទ្ធិនេះ ត្រូវរាប់ទាំងសេរីភាពក្នុងការស្វែងរកព័ត៌មាន ទទួលព័ត៌មាន និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែនឡើយ ទាំងតាមផ្ទាល់មាត់ក្តី, តាមការសរសេរ ឬបោះពុម្ពក្តី, តាមទំរង់សិល្បៈក្តី ឬតាមរយៈចរន្តផ្សាយព័ត៌មានដទៃៗទៀតក្តី ។
៣- ការអនុវត្តន៍សិទ្ធិដែលបានចែងក្នុងវគ្គទី ២ ខាងលើនេះ ត្រូវប្រទះនិងការទទួលខុសត្រូវ និងកាតព្វកិច្ចខ្លះៗ ។ ជួនកាលវាអាចជួបប្រទះនិងការកំរិតលក្ខខណ្ឌ និងបទបញ្ជាផ្សេងៗ ដែលច្បាប់បានបញ្ញត្តិ ជាចាំបាច់ដើម្បីៈ

ក. គោរពសិទ្ធិ និង កិត្តិនាមអ្នកដទៃ

ខ. ការពារសន្តិសុខជាតិ របៀបរៀបរយសាធារណៈ ព្រមទាំងសុខុមាលភាព និងសីលធម៌ សាធារណៈ ។

**មាត្រា ២០ៈ**

១- ច្បាប់ហាមប្រាមជាដាច់ខាតដល់ការឃោសនា ឬការផ្សាយផ្សេងៗដើម្បីបង្កសង្គ្រាម ។
២- ច្បាប់ក៏ហាមជាដាច់ខាតដែរ ចំពោះចលនាបណ្តុះបណ្តាលការស្អប់ខ្ពើមគ្នារវាងជាតិ និងជាតិ រវាងសាសនា និងសាសនា រវាងពូជសាសន៍ និងពូជសាសន៍ ដែលជាកត្តាញុះញង់ឱ្យកើតមានការប្រកាន់ពូជសាសន៍ ការប្រទូស្តរ៉ាយ និងជម្លោះវាយប្រហារដ៏សាហាវយង់ឃ្នងនានា ។

**មាត្រា ២១ៈ**

សិទ្ធិនៃការជួបប្រជុំគ្នាដោយសន្តិវិធី ត្រូវតែបានទទួលស្គាល់ ។ មិនត្រូវឱ្យមានកំរិតលក្ខខណ្ឌអ្វីទៅលើការអនុវត្តន៍សិទ្ធិនេះទេ លើកលែងតែការដាក់កំរិតលក្ខខណ្ឌនោះស្របទៅតាមច្បាប់ និងជាការចាំបាច់ ក្នុងសង្គមប្រជាធិបតេយ្យ ដែលជាប្រយោជន៍ដល់សន្តិសុខជាតិ ឬសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខុមាលភាព ឬសីលធម៌សាធារណៈ ឬការការពារដល់សិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

**មាត្រា ២៦ៈ**

នៅចំពោះមុខច្បាប់ មនុស្សគ្រប់ៗរូបមានសិទ្ធិស្មើៗគ្នា ហើយក៏មានសិទ្ធិទទួលកិច្ចការពារអំពីច្បាប់ដោយស្មើភាពគ្នា ដោយឥតប្រកាន់ពូជសាសន៍ ឬពិណសំបុរឡើយ ។ ក្នុងករណីនេះ ច្បាប់ហាមមិនឱ្យមានការប្រកាន់ពូជសាសន៍ ហើយច្បាប់ធានាជូនបុគ្គលគ្រប់រូបនូវបញ្ញត្តិ ការពារយ៉ាងស័ក្តិសិទ្ធិ កុំឱ្យមានការប្រកាន់ទៅលើពូជសាសន៍ ពណ៌សំបុរ ភេទ សាសនា ភាសា ជំហរនយោបាយ មតិនានា កំណើតជាតិ ឬសង្គម ឋានៈ វណ្ណៈ ឬអ្វីផ្សេងៗទៀតឡើយ ។

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR)

**មាត្រា ៦ៈ**

១- រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់នូវសិទ្ធិ ដើម្បីមានការងារធ្វើ ហើយត្រូវចាត់វិធានការថែរក្សាសិទ្ធិនេះឱ្យបានសមរម្យ ។ សិទ្ធិនេះមានរាប់បញ្ចូលទាំងសិទ្ធិរបស់មនុស្សគ្រប់ៗរូប ដើម្បីមានឱកាសនឹងរស់នៅ ដោយធ្វើការងារដែលគេបានជ្រើសរើស ឬទទួលយកដោយសេរី ។

២- វិធានការដែលរដ្ឋជាភាគីនិមួយៗប្រកាន់យក ដើម្បីឱ្យបានសំរេចលទ្ធផលពេញលេញតាមបញ្ញត្តិនៃសិទ្ធិនេះ ត្រូវរាប់បញ្ចូលផលដែរនូវកម្មវិធីហ្វឹកហ្វឺន និងណែនាំខាងវិស័យបច្ចេកទេស និងវិជ្ជាជីវៈ គោលការណ៍ច្បាប់ និងបច្ចេកវិធីនានា ដើម្បីធ្វើឱ្យមានការអភិវឌ្ឍន៍ជាលំដាប់ខាងវិស័យសេដ្ឋកិច្ច វិស័យសង្គម និងវប្បធម៌ ព្រមទាំងមានការងារសំរាប់ឱ្យមនុស្សធ្វើឱ្យបានគ្រប់គ្រាន់ និងប្រកបដោយផលប្រយោជន៍ផង ។ ហើយការងារទាំងនោះត្រូវស្ថិតនៅក្នុងលក្ខខណ្ឌដើម្បីរក្សាការពារមូលដ្ឋាននៃសេរីភាពរបស់មនុស្សក្នុងផ្នែកនយោបាយ និងសេដ្ឋកិច្ច ។

## សេចក្តីថ្លែងការស្តីពីសិទ្ធិជនពិការ (DRDP)

### ប្រការ ៧:

ជនពិការ មានសិទ្ធិសេដ្ឋកិច្ច និងសន្តិសុខសង្គម និងសិទ្ធិមានជីវភាពរស់នៅសមរម្យ ។ ដោយយោងតាមសមត្ថភាពរបស់ពួកគេ ពួកគេមានសិទ្ធិទទួលបាននូវការធានា និងរក្សា ឱ្យនូវការងារ ឬទទួលបាននូវការសន្យាផ្តល់នូវមុខរបរមួយដែលមានប្រយោជន៍ លក្ខណៈច្នៃប្រឌិត និងផ្តល់នូវប្រាក់កំរៃ និងសិទ្ធិចូលរួមក្នុងសហជីព ។

# ខ) បទដ្ឋានច្បាប់ជាតិ

## ១) ច្បាប់

## ច្បាប់ស្តីពីការងារ

### មាត្រា ៣៩០:

បទប្បញ្ញត្តិនៃច្បាប់នេះ អាចអនុវត្តបានដោយពេញច្បាប់ទៅលើកិច្ចសន្យាការងារជាបុគ្គលដែលកំពុងនៅមានអាយុកាល ប៉ុន្តែបើកម្មករនិយោជិត បានទទួលអត្ថប្រយោជន៍តាមកិច្ចសន្យានោះ ច្រើនជាងអត្ថប្រយោជន៍ដែលមានចែងក្នុងច្បាប់នេះ កម្មករនិយោជិត ត្រូវមានសិទ្ធិទទួលអត្ថប្រយោជន៍អំពីកិច្ចសន្យារបស់ខ្លួនបន្តទៅទៀត ។

បទប្បញ្ញត្តិនៃច្បាប់នេះ មិនអាចជាហេតុនាំឱ្យផ្តាច់កិច្ចសន្យាទេ ។

### មាត្រា ៣៩២:

ក្នុងអន្តរកាល និងរហូតដល់កាលបរិច្ឆេទ ដែលនឹងកំណត់ដោយប្រកាសក្រសួងទទួល បន្ទុកវិស័យការងារ រាល់អង្គការសហជីពនៃកម្មករនិយោជិត អាចបញ្ជូនបេក្ខជនទៅចូលរួមក្នុងការបោះឆ្នោតលើកទី ១ សំរាប់ការជ្រើសរើសប្រតិភូបុគ្គលិក ដោយមិនបាច់រកភស្តុតាងបញ្ជាក់នូវភាពជាតំណាងនោះទេ។

ក្នុងរយៈពេលខាងលើនេះ អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត និងអង្គការវិជ្ជាជីវៈរបស់និយោជកដែលអះអាងថាមានភាពជាតំណាងនៅតាមផ្នែកវិជ្ជាជីវៈ និងភូមិសាស្ត្ររបស់ខ្លួន អាចសំរេចលើអនុសញ្ញារួមដែលគ្របដណ្តប់លើដែនអនុវត្តនៃផ្នែកវិជ្ជាជីវៈ និងភូមិសាស្ត្រនោះ ។ ទោះយ៉ាងណាក៏ដោយ ក៏តំលៃនៃអនុសញ្ញានោះត្រូវតែបញ្ចប់យ៉ាងយូរបំផុតក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីថ្ងៃចេញផ្សាយជាសាធារណៈ នូវប្រកាសដែលមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ ។ ការដាក់ឱ្យប្រើអនុសញ្ញារួមជាថ្មី ឬការធ្វើអនុសញ្ញារួមថ្មី អាចធ្វើបានតែក្នុងក្របខ័ណ្ឌនៃមាត្រា៩៦ ។

ក្នុងពេលរង់ចាំការទទួលស្គាល់អង្គការវិជ្ជាជីវៈ ដែលមានភាពជាតំណាងថ្នាក់ជាតិ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ នឹងជ្រើសរើសនូវឥស្សរជន ដែលគេទទួលស្គាល់ថាមានគុណសម្បត្តិពិសេសក្នុងវិស័យសង្គមកិច្ច ឬក្នុងវិស័យមុខរបរ និងការងារ ដើម្បីកាន់កាប់អាសនៈទាំងឡាយសំរាប់តំណាងកម្មករនិយោជិត និងតំណាងនិយោជក។

### មាត្រា ៣៩៥:

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

## ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### មាត្រា ៤៣:

ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋានរដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវ កិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្ត ឱ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សា បរិស្ថាន ធនធានធម្មជាតិ
- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់ អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

### មាត្រា ៤៧:

តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា៤២ ,៤៣ ,៤៤ និងមាត្រា៤៥ នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀត ដោយអនុក្រិត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ

**មាត្រា ៩:**

ក្នុងការរកចំនួនអាសនៈថ្មីរបស់រដ្ឋសភា ត្រូវគណនាតាមរូបមន្តដូចខាងក្រោមដោយមិនគិតចំនួនសល់

$$\frac{\text{ប}_{\text{ម}}}{\text{ច}_{\text{ម}}} = \text{ផ}$$

- $\text{ប}_{\text{ម}}$ ជាចំនួនប្រជាពលរដ្ឋខ្មែរ នៅពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចុងក្រោយកន្លងមកនេះ ។
- $\text{ច}_{\text{ម}}$ ជាចំនួនអាសនៈក្នុងរដ្ឋសភាបច្ចុប្បន្ន ។
- ផ ជាផលចែកប្រភាគដោយពុំគិតចំនួនសល់ ។

$$\frac{\text{ប}_{\text{ប}}}{\text{ផ}} = \text{ច}_{\text{ថ}}$$

- $\text{ប}_{\text{ប}}$ ជាចំនួនប្រជាពលរដ្ឋខ្មែរបច្ចុប្បន្ន ។
- $\text{ច}_{\text{ថ}}$ ជាចំនួនអាសនៈថ្មីដោយពុំគិតចំនួនសល់ ។

ក្នុងការរកចំនួនអាសនៈតាមខេត្ត ក្រុង ត្រូវគណនាតាមរូបមន្តដូចខាងក្រោម:

$$\frac{\text{ប}}{\text{ផ}} = \text{ច}$$

- ប ជាចំនួនប្រជាពលរដ្ឋខ្មែរក្នុងខេត្ត ក្រុង ។
- ផ ជាផលចែកប្រភាគដែលបានមកពីការគណនាខាងលើ ។
- ច ជាចំនួនអាសនៈថ្មីក្នុងខេត្ត ក្រុង ដោយពុំគិតចំនួនសល់ ។

**មាត្រា ១១៨:**

ក. ក្រោយពីបណ្តឹងតវ៉ាត្រូវបានសម្រេចជាស្ថាពរ និងក្រោយពីបានទទួលលទ្ធផលនៃការបោះឆ្នោតទាំងអស់ រួមទាំងលទ្ធផលនៃការបោះឆ្នោតដែលត្រូវធ្វើសាជាថ្មី ប្រសិនបើ មានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាផ្លូវការលទ្ធផលនៃការបោះឆ្នោត ហើយកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយនីមួយៗតាមមណ្ឌលនីមួយៗ ដោយគិតតាមចំនួនសន្លឹកឆ្នោតបានការ ។

ការបែងចែកអាសនៈតាមខេត្ត ក្រុង ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដោយផ្អែកលើចំនួនអាសនៈក្នុងខេត្ត ក្រុង និងលទ្ធផលនៃការបោះឆ្នោតក្នុងខេត្ត ក្រុង តាមជំហានទាំងឡាយ ដូចខាងក្រោម:

**ជំហានទី ១**: កំណត់ចំនួនកូតាដែលតម្រូវឱ្យគណបក្សនយោបាយណាមួយទទួលអាសនៈមួយ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបនៅក្នុងខេត្ត ក្រុង មកចែកនឹងចំនួនអាសនៈសរុបក្នុងខេត្ត ឬក្រុង តាមរូបមន្តដូចខាងក្រោមនេះ និងត្រូវអនុវត្តដាច់ដោយឡែកពីគ្នា សម្រាប់ខេត្ត ក្រុងនីមួយៗ

$$\text{ក}_{\text{ត}} = \frac{\text{ស}_{\text{ស}}}{\text{អ}_{\text{ស}}}$$

ក្នុងនោះ:

- $\text{ក}_{\text{ត}}$ : តាងឱ្យកូតាជាផលចែក ដោយមិនគិតសំណល់ចែក ។

- $ស_{ស}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឱ្យគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងខេត្ត ក្រុង ។
- $អ_{ស}$ : តាងឱ្យចំនួនអាសនៈសរុបតាមមណ្ឌលខេត្ត ក្រុង ។

**ជំហានទី២**: កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួលនៅក្នុងខេត្ត ក្រុង។

រូបមន្តដូចខាងក្រោម ត្រូវអនុវត្តដាច់ដោយឡែកពីគ្នា សម្រាប់គណបក្សនយោបាយនីមួយៗ ដែលបានចូលរួមនៅក្នុងការបោះឆ្នោតនៅក្នុងខេត្ត ក្រុងៈ

$$អ_{ទ} = \frac{ស_{ប}}{ក_{ត}}$$

ក្នុងនោះ:

- $អ_{ទ}$ : ជាផលចែកដោយមិនគិតសំណល់ចែក តាងឱ្យចំនួនអាសនៈដែល គណបក្សនយោបាយនីមួយៗ មានសិទ្ធបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី៣ ។
- $ស_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឱ្យគណបក្សនយោបាយណាមួយ នៅក្នុងខេត្ត ក្រុង ។
- $ក_{ត}$ : តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី ១ ។

បន្ទាប់ពីគណនា គ្រប់គណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងខេត្ត ក្រុង ក្នុងជំហានទី ២ ប្រសិនបើគ្មានអាសនៈនៅសល់ ដើម្បីបែងចែកបន្តទៀតនោះ ចំនួនអាសនៈត្រូវសម្រេចកំណត់យកតែម្តង ។

ក្នុងករណីមានអាសនៈនៅសល់ត្រូវបន្តបែងចែក បន្ទាប់ពី ធ្វើការគណនាសម្រាប់គណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងខេត្ត ក្រុង អាសនៈដែលនៅសល់ទាំងនេះ ត្រូវកំណត់ទៅតាមរបៀបដែលបានកំណត់ ក្នុងជំហានទី ៣ ។

**ជំហានទី ៣**: អាសនៈដែលនៅសល់ ត្រូវបែងចែកឱ្យគណបក្សនយោបាយនីមួយៗ មានសិទ្ធិបានទទួលនៅក្នុងខេត្ត-ក្រុង ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត ។ រូបមន្តដូចខាងក្រោម ត្រូវអនុវត្តដាច់ដោយឡែកពីគ្នាសម្រាប់ គណបក្សនយោបាយនីមួយៗ ដែលបានចូលរួមក្នុងការបោះឆ្នោតតាមខេត្ត ក្រុងៈ

$$ម_{ធ} = \frac{ស_{ប}}{អ_{ទ}+១}$$

ក្នុងនោះ:

- $ម_{ធ}$ : តាងឱ្យមធ្យមភាគខ្ពស់បំផុត ។
- $ស_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឱ្យគណបក្សនយោបាយមួយ ។
- $អ_{ទ}$ : តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យគណបក្សនយោបាយមួយ ។

ក្នុងករណីដែលនៅសល់អាសនៈចំនួនមួយដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្ត ក្នុងជំហានទី ៣ សម្រាប់គណបក្សនយោបាយដែលមានលក្ខណៈសម្បត្តិទាំងអស់ អាសនៈនោះ ត្រូវបែងចែកទៅឱ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។

ក្នុងករណីដែលនៅសល់អាសនៈច្រើនជាងមួយដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុងជំហានទី៣ ហើយអាសនៈចំនួនមួយ ត្រូវបែងចែកទៅឱ្យគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត។ បន្ទាប់មកត្រូវអនុវត្តរូបមន្តនេះម្តងទៀត ដោយបង្កើនតម្លៃ អ$_១$ ចំនួន ១ ចំពោះគណបក្សនយោបាយដែលបានទទួលអាសនៈចំនួនមួយក្នុងការអនុវត្តន៍រូបមន្តលើកទីមួយ ។ ដូច្នេះចំនួនអាសនៈចំនួនមួយ ត្រូវផ្តល់ឱ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ក្នុងការអនុវត្តន៍រូបមន្តលើកទីពីរក្នុងករណីនៅសល់អាសនៈ ត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកអាសនៈម្តងមួយអាសនៈជាបន្តបន្ទាប់ រហូតដល់អស់អាសនៈដែលនៅសល់ ។

ខ. ការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ ត្រូវអនុលោមទៅតាមបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងអនុវត្តតាមលំដាប់លេខរៀងដូចមានចែងក្នុងមាត្រា ៣៨ថ្មី នៃច្បាប់នេះ ។

គ. ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតមានអ្នកជាប់ឆ្នោតទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពតំណាងរាស្ត្រ បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនោះ ត្រូវបានប្រកាសថា ជាប់ឆ្នោតជាតំណាងរាស្ត្ររបស់សាមីគណបក្សនយោបាយ ។

ឃ. ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយមានបេក្ខជនមិនគ្រប់គ្រាន់ ដោយមូលហេតុដូចមានចែងក្នុងចំណុច គ នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះ ឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលដប់បួន (១៤) ថ្ងៃក្រោយពីបានទទួលសំណើ ។

បែបបទនៃការទទួលពិនិត្យ និងអនុម័តបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុង មាត្រា ៣៣ថ្មី មាត្រា ៣៤ថ្មី មាត្រា ៣៥ថ្មី មាត្រា ៣៦ថ្មី មាត្រា ៣៨ថ្មី មាត្រា ៤១ថ្មី មាត្រា ៤២ថ្មី មាត្រា ៤៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាកំណត់ខាងលើ ឬមិនបានកែលំអការខ្វះខាតដែលធ្វើឱ្យគណបក្សនយោបាយនោះ មិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះ បោះបង់ចោលអាសនៈឱ្យនៅទំនេរ ។

ង. ក្នុងករណីគណបក្សនយោបាយណាមួយបានទទួលអាសនៈមួយ ឬច្រើននៅក្នុងរដ្ឋសភា ប៉ុន្តែគណបក្សនយោបាយនោះបានប្រកាសបោះបង់ចោលអាសនៈរបស់ខ្លួន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយ តាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងបេក្ខជននៃគណបក្សនយោបាយនោះដែលបានប្រកាសថា ជាប់ឆ្នោតរួចហើយ មិនមានសុពលភាព និងមិនមានគុណសម្បត្តិតទៅទៀតបានឡើយ ។

ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈ ដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរប្រាំពីរ (៧) ថ្ងៃ ទៅឱ្យគណបក្សនយោបាយផ្សេងដែល ទទួលបានអាសនៈក្នុងខេត្ត ក្រុង ជាមួយ តាមជំហានទាំងទឡាយដូចខាងក្រោម ដោយមិនគិតបញ្ចូលគណបក្ស នយោបាយដែលបោះបង់អាសនៈ ។

**ជំហានទី ១**: កំណត់កូតាដែលតម្រូវឱ្យគណបកសនយោបាយបានទទួលមួយអាសនៈ តាមរូបមន្តដូចខាងក្រោមៈ

$$\text{ក}'_{\text{ត}} = \frac{\text{ស}'_{\text{ក}}}{\text{អ}'_{\text{ប}}}$$

ក្នុងនេះ:

- ក់$_{\text{ត}}$ : តាងឱ្យកូតាជាផលចែកដោយមិនគិតសំណល់ចែក ។
- ស់$_{\text{ស}}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយទាំងអស់ដែលទទួលអាសនៈក្នុងការបោះឆ្នោតនៅក្នុងខេត្ត-ក្រុង ដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឱ្យគណបក្សនយោបាយដែលបោះបង់អាសនៈនៅក្នុងខេត្ត ក្រុង ។
- អ់$_{\text{ប}}$ : តាងឱ្យអាសនៈដែលបានបោះបង់ចោលនៅក្នុងខេត្ត ក្រុង ។

**ជំហានទី ២**: កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួលតាមរូបមន្តដូចខាងក្រោមៈ

$$\text{អ}'_{\text{ន}} = \frac{\text{ស}_{\text{ប}}}{\text{ក}'_{\text{ត}}}$$

ក្នុងនោះ:

- អ់$_{\text{ទ}}$ : តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយក្នុងខេត្ត ក្រុង បានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទី ៣ ។
- ស$_{\text{ប}}$ : តាងឱ្យសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយមួយក្នុង ខេត្ត ក្រុង ។
- ក់$_{\text{ត}}$ : តាងឱ្យចំនួនកូតាដែលបានកំណត់ក្នុងជំហានទី ១ ។

បន្ទាប់ពីបានគណនាក្នុងជំហានទី ២ គ្រប់គណបក្សនយោបាយដែលទទួលបានអាសនៈក្នុងខេត្ត ក្រុង លើកលែងតែគណបក្សនយោបាយដែលបោះបង់អាសនៈក្នុងខេត្ត ក្រុង ក្នុងករណីគ្មាននៅសល់អាសនៈ ដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីគណនាក្នុងជំហានទី ២ រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកតទៅទៀត អាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តដែលបានកំណត់ក្នុងជំហានទី ៣ ។

**ជំហានទី ៣**: អាសនៈដែលនៅសល់ ត្រូវបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្ត ដូចខាងក្រោមៈ

$$\text{ម}'_{\text{ឌ}} = \frac{\text{ស}_{\text{ប}}}{\text{អ}'_{\text{ន}}+១}$$

ក្នុងនោះ:

- ម់$_{\text{ឌ}}$ :តាងឱ្យមធ្យមភាគខ្ពស់បំផុត ។
- ស$_{\text{ប}}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឱ្យគណបក្សនយោបាយមួយក្នុងខេត្ត ក្រុង ។
- អ់$_{\text{ទ}}$ : តាងឱ្យចំនួនអាសនៈ ដែលបានបែងចែកឱ្យទៅគណបក្សនយោបាយមួយ ។

វិធីសាស្ត្រដូចមានចែងក្នុងវាក្យខ័ណ្ឌទី៩ និងវាក្យខ័ណ្ឌទី១០ ចំណុច ក នៃមាត្រានេះ ត្រូវអនុវត្តចំពោះការគណនាក្នុងជំហានទី ៣ និងការគណនាជាបន្តបន្ទាប់ទៀត ។

ច. ក្នុងករណីគណនាតាមរូបមន្តខាងលើ មានគណបក្សពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នាដែលមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ទៅឱ្យគណបក្សណាមួយបាន អាសនៈនោះ ត្រូវផ្តល់ជូនទៅគណបក្សនយោបាយ ដែលទទួលបានចំនួនសន្លឹកឆ្នោតបានការខ្ពស់ជាងគេ ។ ក្នុងករណីចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយស្មើគ្នាទៀតនោះ អាសនៈដែលនៅសល់នោះ ត្រូវបែងចែកទៅឱ្យគណបក្សនយោបាយតាមការចាប់ឆ្នោត ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ។

ឆ. ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួន មានបេក្ខជនតិចជាងអាសនៈនោះ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុច ឃ នៃមាត្រានេះ ។

ជ. ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ក នៃមាត្រានេះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលនីមួយៗ ជាបន្តបន្ទាប់ ។

ឈ. មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើសេចក្តីរាយការណ៍ជូនគ្រប់តំណាងគណបក្សនយោបាយ ដែលចូលរួមបោះឆ្នោត នូវចំនួនសន្លឹកឆ្នោតសរុបដែលបានបោះពុម្ពចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងចំនួនសន្លឹកឆ្នោតដែលនៅសល់ ។

## ច្បាប់ស្តីពីរបបសារព័ត៌មាន

**មាត្រា ៣:**

ដើម្បីរក្សាឯករាជ្យនៃសារព័តិមាន ការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយ ត្រូវហាមឃាត់ ។

**មាត្រា ៤:**

ការបោះពុម្ពផ្សាយនូវព័តិមានផ្លូវការដូចជា សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ណាមួយ ។ល។ មិនអាចត្រូវផ្តន្ទាទោសបានឡើយ ប្រសិនបើការផ្សាយនោះមានលក្ខណៈសមស្របតាមសភាពពិតពេញលេញ ឬសេចក្តីសង្ខេបត្រឹមត្រូវតាមរឿងពិត ។

**មាត្រា ១២ កថាខ័ណ្ឌទី ១:**

សារព័តិមាន មិនត្រូវបោះពុម្ពផ្សាយឬផ្សាយបន្តនូវព័តិមានដែលបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ ។

## ច្បាប់ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ១០ កថាខ័ណ្ឌទី ៣:**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញណា ដែលត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារពីបទមជ្ឈិម ឬឧក្រិដ្ឋ ត្រូវដកចេញពីមុខតំណែងជាស្វ័យប្រវត្តិ ។

## ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

**មាត្រា ២៩ កថាខ័ណ្ឌទី ១ និងទី ៤:**

អ្នកបើកបររថយន្តគ្រប់ប្រភេទ ត្រាក់ទ័រ ត្រីចក្រយានយន្ត និងទោចក្រយានយន្តដែលមានចំណុះស៊ីឡាំង ចាប់ពី ១០០សង់ទីម៉ែត្រគីប ឡើងទៅ ត្រូវមានប័ណ្ណបើកបរចេញដោយក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ ។

អ្នកសុំបើកបរត្រូវពិនិត្យកាយសម្បទានៅក្រសួង មន្ទីរ ឬការិយាល័យសុខាភិបាលជាមុន ។

## ច្បាប់ស្តីពីការធ្វើបាតុកម្ម

**មាត្រា ២ កថាខ័ណ្ឌទី ៣:**

ការប្រមូលផ្តុំគ្នាដើរតាមផ្លូវសាធារណៈ ជាបាតុកម្មសំដែងមតិលើបញ្ហាអ្វីមួយនឹងអាចប្រព្រឹត្តទៅបានតែ ក្នុងលក្ខខណ្ឌ ដូចខាងក្រោម :

.....

៣- ត្រូវជំរាបជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរឃុំ សង្កាត់នីមួយៗ ដែលបាតុកម្មត្រូវឆ្លងកាត់យ៉ាងតិច ៣ថ្ងៃមុន ដោយមានចុះនាមត្រកូល នាមខ្លួន អាស័យដ្ឋាន និងហត្ថលេខាអ្នករៀបចំបាតុកម្ម ៣នាក់ ព្រមទាំង បញ្ជាក់គោលបំណងនៃបាតុកម្ម ទីកន្លែង ថ្ងៃ ខែ ឆ្នាំ ម៉ោងនៃការប្រជុំ ផ្លូវ និងចំនួនដែលត្រូវដង្ហែរក្បួនបាតុកម្ម ។

បើបាតុកម្មធ្វើនៅទីរួមខេត្ត ឬនៅរដ្ឋធានី ត្រូវជំរាបជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរទីរួមខេត្ត ឬទៅ អាជ្ញាធររដ្ឋធានី ។

**មាត្រា ៣ កថាខ័ណ្ឌទី ១ និង ២:**

អាជ្ញាធរដែលបានទទួលលិខិតជូនដំណឹង ត្រូវចេញបង្កាន់ដៃមួយឱ្យ ។

បើអាជ្ញាធរសាមីឃើញថា បាតុកម្មមានលក្ខណៈដែលអាចនាំឱ្យកើតមានចលាចលនោះ អាជ្ញាធរសាមី អាចហាមឃាត់បាតុកម្ម ដោយចេញសេចក្តីសំរេចមួយក្នុងរយៈពេល ៤៨ម៉ោង ហើយឱ្យដំណឹងអំពីសេចក្តីសំរេច នោះដល់អ្នករៀបចំបាតុកម្មវិញភ្លាម ។

**មាត្រា ៤ កថាខ័ណ្ឌទី ១:**

កាលបើមានបាតុកម្មកើតឡើងដោយមិនបានជំរាបអាជ្ញាធរមូលដ្ឋានជាមុន ឬដោយអាជ្ញាធរមូលដ្ឋាន មិនបានអនុញ្ញាត អាជ្ញាធរមូលដ្ឋានអាចចាត់វិធានការឃាត់បាតុករដល់ទីកន្លែង ។

## ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

### មាត្រា ៣៥:

នគរបាលយុត្តិធម៌ស្វែងរកបទល្មើសឧក្រិដ្ឋ បទមជ្ឈិម និងបទលហុទាំងឡាយ ប្រមូលភស្តុតាង ហើយបញ្ជូនជនល្មើសទៅសាលាជំរះក្តី ដែលមានភារកិច្ចផ្តន្ទាទោសជនទាំងនោះ ។ ប៉ុន្តែនឹងអាចត្រូវបានចាប់បញ្ជូនទៅសាលាជំរះក្តីដោយនគរបាលយុត្តិធម៌ តែក្នុងករណីដែលជនល្មើសបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ ឬកាលណាមានដីកាបង្គាប់ឱ្យនាំខ្លួន ឬដីកាចាប់ខ្លួនជនល្មើស ។

### មាត្រា ៣៦:

ចាត់ទុកជាមន្ត្រីនគរបាលយុត្តិធម៌ ឬអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌រួមមាន:

១- រដ្ឋអាជ្ញា និងចៅក្រមទទួលបន្ទុកស៊ើបអង្កេត" ក្នុងភារកិច្ចតែប៉ុណ្ណោះ "
២- ប្រធាន និងអនុប្រធានទាំងឡាយ នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ និងសេដ្ឋកិច្ច
៣- ប្រធាន និងអនុប្រធានទាំងឡាយ នៃនាយកដ្ឋានប្រឆាំងភេរវកម្ម
៤- ស្នងការ និងស្នងការរងទាំងឡាយ នៃនគរបាលខេត្ត-ក្រុង
៥- ប្រធានការិយាល័យនគរបាលព្រហ្មទណ្ឌ និងសេដ្ឋកិច្ច
៦- ប្រធានការិយាល័យប្រឆាំងភេរវកម្ម
៧- ប្រធានការិយាល័យនគរបាលសន្តិសុខ
៨- អធិការ និងអធិការរងនគរបាលនយោបាយស្រុក-ទីរួមខេត្ត
៩- ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល "ចំពោះរឿងព្រហ្មទណ្ឌ "
១០- ប្រធានការិយាល័យនគរបាលចរាចរ និងប្រធានផ្នែកបទល្មើសចរាចរ "ចំពោះបទល្មើសចរាចរ"
១១- ប្រធាន និងមន្ត្រីទាំងឡាយនៃកងតម្រួតយោធា" ចំពោះបទល្មើសយោធា "
១២- មន្ត្រីនគរបាលព្រំដែន
១៣- អធិការគយ" ចំពោះបទល្មើសគយ"
១៤- មន្ត្រីរុក្ខាប្រមាញ់ និងនេសាទ

ប្រតិបត្តិការទាំងឡាយនៃនគរបាលយុត្តិធម៌ ស្ថិតក្រោមការដឹកនាំផ្ទាល់របស់រដ្ឋអាជ្ញា និងក្រោមការត្រួតពិនិត្យ របស់អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ ។

### មាត្រា ៣៧:

មន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចចាត់ចែងប្រតិបត្តិការ គឺ:

- មន្ត្រីនគរបាលយុត្តិធម៌ នៅកន្លែងដែលបទល្មើសព្រហ្មទណ្ឌកើតមាន
- មន្ត្រីនគរបាលយុត្តិធម៌ ខាងលំនៅដ្ឋានរបស់ជនល្មើស
- ឬមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងដែលជនល្មើសត្រូវបានរកឃើញ

**មាត្រា ៣៨:**

មន្ត្រីនគរបាលយុត្តិធម៌:

- ទទួលពាក្យបណ្តឹងទាមទារបណ្តឹងបរិហារ ព្រមទាំងរបាយការណ៍នគរបាលយុត្តិធម៌ទាក់ទង បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុនានា ។
- ចាត់ចែងប្រមូលភស្តុតាងនានា ។
- អាចស្នើសុំជំនួយពីកំលាំងសាធារណៈ ។
- ធ្វើកំណត់ហេតុ ។
- អាចទទួលលិខិតបង្គាប់ឱ្យសួរជំនួស ។
- អាចសំរេចឃាត់ខ្លួនបានក្នុងរយៈពេល ៤៨ ម៉ោងយ៉ាងយូរ ។
- ក្នុងករណីរឿងឧក្រិដ្ឋ និងមជ្ឈិមជាក់ស្តែង អាចសួរយកចម្លើយសាក្សី ធ្វើការឆែកឆេរ និងរឹបអូស វត្ថុតាង អាចចាត់តាំងអ្នកជំនាញសំរេចឃាត់ខ្លួនជនល្មើស "៤៨ម៉ោង យ៉ាងយូរ" ចាប់បុគ្គល ណាមួយ ប្រសិនបើ មានភស្តុតាង ឬមានការសង្ស័យដែលមានមូលដ្ឋានច្បាស់ សមស្របធ្វើ ការចោទប្រកាន់បាន ។

**មាត្រា ៣៩:**

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវកត់ត្រាក្នុងលិខិតជាលាយល័ក្ខអក្សរដែលហៅថា "កំណត់ហេតុ" នូវការពិនិត្យ ឃើញរបស់ខ្លួន និងលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួន ។

តាមគោលការណ៍ កំណត់ហេតុមិនមែនជាមូលដ្ឋានចាំបាច់នៃការចោទប្រកាន់ទេ ។ កំណត់ហេតុនោះគ្រាន់ តែផ្តល់ធាតុផ្សំទាំងឡាយ នៃបទល្មើសសំរាប់ជាមូលវិចារណ៍របស់អយ្យការ និងចៅក្រមតែប៉ុណ្ណោះ ។

**មាត្រា ៤០:**

កំណត់ហេតុត្រូវកត់គោត្តនាម នាម និងមុខងាររបស់អ្នកធ្វើកំណត់ហេតុ ។ អ្នកធ្វើកំណត់ហេតុ ត្រូវចុះ ហត្ថលេខា និងកាលបរិច្ឆេទក្នុងកំណត់ហេតុ ហើយត្រូវធ្វើកំណត់ហេតុនោះជាបន្ទាន់កុំឱ្យមានការយឺតយ៉ាវឡើយ ។ ការឆូត លុប ឬការបន្ថែមសេចក្តីទាំងឡាយ ត្រូវមានសេចក្តីបញ្ជាក់ ។

**មាត្រា ៤១:**

តាមគោលការណ៍ កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ។ អាចនិយាយបាន ម្យ៉ាងទៀតថា កំណត់ហេតុ មានតម្លៃជាសេចក្តីរាយការណ៍ ហើយមិនបង្ខំសាលាជំរះក្តី ឬចៅក្រមត្រូវតែជឿនោះទេ ។

**មាត្រា ៤២:**

ប៉ុន្តែកំណត់ហេតុរបស់នគរបាលយុត្តិធម៌ ត្រូវទុកជាបន្ទាល់ "ឯកសារដើម" បានន័យថា ត្រូវទុកជាឯកសារ ដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ កាលបើកំណត់ហេតុទាំងនោះធ្វើឡើងដោយមន្ត្រីយុត្តិធម៌ខ្លួនឯង ។ ក្នុងករណីនេះ ចៅក្រមត្រូវទុកខ្លឹមសាររបស់កំណត់ហេតុថាជាសេចក្តីពិត និងត្រឹមត្រូវដរាបណាដែលគ្មានភស្តុតាង

អ្វីផ្ទុយមកបញ្ជាក់ទេនោះ ។ ភស្តុតាងផ្ទុយនេះ អាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។

**មាត្រា ៤៣:**

ចំពោះបទលហុ កំណត់ហេតុរបស់នគរបាលយុត្តិធម៌ ទុកជាបន្ទាល់ដរាបរហូតដល់មានភស្តុតាងផ្ទុយ ។ លក្ខខណ្ឌមានតែមួយទេ គឺភ្នាក់ងារធ្វើកំណត់ហេតុត្រូវតែមានគុណសម្បត្តិដើម្បីពិនិត្យបទលហុនោះ ។

**មាត្រា ៤៤:**

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូនក្នុងរយៈពេលដ៏ខ្លីបំផុតនូវកំណត់ហេតុរបស់ខ្លួន ព្រមទាំងវត្ថុតាងភ្ជាប់ជាមួយផង ទៅរដ្ឋអាជ្ញាអមសាលាជំរះក្តីមានសមត្ថកិច្ច ។

**មាត្រា ៤៥:**

មន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិពិនិត្យបញ្ជាក់ផ្ទាល់ នូវបទល្មើសព្រហ្មទណ្ឌទាំងឡាយ លើកលែងតែបទល្មើសខ្លះ ដែលច្បាប់តម្រូវឱ្យមានពាក្យប្តឹងជាមុនដាច់ខាត ។

**មាត្រា ៤៦:**

មន្ត្រីនគរបាលយុត្តិធម៌ ក៏មានសិទ្ធិកត់ត្រាចម្លើយសាក្សី និងមានសិទ្ធិឆែកឆេរលំនៅដ្ឋានផងដែរ ប៉ុន្តែសិទ្ធិឆែកឆេរលំនៅដ្ឋាននេះ នឹងអាចធ្វើទៅបានតែកាលណាមានរឿងឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងតែប៉ុណ្ណោះ ។

**មាត្រា ៤៧:**

មានតែក្នុងករណីបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងប៉ុណ្ណោះទេ ទើបមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិចាប់ខ្លួនជនប្រព្រឹត្តបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវនាំខ្លួនជនល្មើសក្នុងរយៈពេល ៤៨ម៉ោង យ៉ាងយូរទៅប្រគល់ជូនចៅក្រមមានសមត្ថកិច្ច ដោយមិនគិតដល់ពេលវេលាចាំបាច់សំរាប់បញ្ជូនជនល្មើសតាមមធ្យោបាយយ៉ាងឆាប់បំផុតដែលអាចធ្វើបាន ។

ក្នុងករណីមិនគោរពវិធានខាងលើនេះទេ នោះត្រូវទទួលការផ្តន្ទាទោសតាម <u>មាត្រា ២២</u> និង <u>មាត្រា ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល</u> ។

**មាត្រា ៤៨:**

ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌ គ្មានសិទ្ធិតំកល់ទុកឥតចាត់ការនូវរឿងអាជ្ញាដែលខ្លួនបានទទួល ទោះមានការសំរុះសំរួលព្រមព្រៀងគ្នាហើយក៏ដោយ គឺត្រូវធ្វើកំណត់ហេតុបញ្ជូនទៅរដ្ឋអាជ្ញាមានសមត្ថកិច្ចជាដរាប ។

ក្នុងករណីមិនគោរពវិធានខាងលើនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលការផ្តន្ទាទោស ដែលមានចែងក្នុងមាត្រា ២២ និងមាត្រា ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

# ២) ពន្ធនាគារ

## ពន្ធនាគារស្ដីពីសមាគម និងអង្គការក្រៅរដ្ឋាភិបាល

### មាត្រា ១២:

អង្គការដឹកនាំរបស់សមាគមនីមួយៗ ត្រូវមានយ៉ាងតិចៈ ប្រធាន គណៈកម្មាធិការនាយក ហិរញ្ញិក និងមហាសន្និបាត ។ អាណត្តិ ភារកិច្ច និងនីតិវិធីបោះឆ្នោត (ការដកសិទ្ធិ និងប្រគល់សិទ្ធិបោះឆ្នោត) ការសំរេចចិត្តលើបញ្ហាអ្វីមួយ ត្រូវកំណត់នៅក្នុងលក្ខន្តិកៈ ។

### មាត្រា ១៤:

ក្រសួងមហាផ្ទៃ ពិនិត្យភាពស្របច្បាប់នៃលក្ខន្តិកៈរបស់សមាគម ដែលស្នើសុំចុះបញ្ជី ។ លក្ខន្តិកៈត្រូវសរសេរជាភាសាខ្មែរ និងមានចំណុចសំខាន់ៗយ៉ាងតិច ដូចតទៅ:

១- អត្តសញ្ញាណនៃសមាគមៈ ឈ្មោះ សញ្ញាសំគាល់ អាស័យដ្ឋាន ទីស្នាក់ការកណ្ដាល គោលបំណង និងឧប្បនិស្ស័យ ។

២- អង្គការដឹកនាំសំខាន់ៗនៃសមាគមៈ ប្រធាន គណៈកម្មាធិការនាយក ហិរញ្ញិក និងមហាសន្និបាត ។

៣- របបនៃការប្រជុំប្រចាំឆ្នាំនៃសមាគមៈ ចំនួននៃកិច្ចប្រជុំប្រចាំឆ្នាំនៃអង្គការនានា ចំនួនកូរ៉ុមវត្តមានចាំបាច់ដើម្បីសំរេចទទួលបានសុពលភាព វិធាននៃការបោះឆ្នោត និងសំលេងភាគច្រើន ដែលទទួលយកជាករណីទូទៅ ឬក្នុងករណីពិសេស ។

៤- ប្រភពធនធានរបស់សមាគមៈ វិធាន និងនីតិវិធីនៃការចាត់ចែងគ្រប់គ្រងធនធាន ។

៥- វិធាននៃការកែប្រែលក្ខន្តិកៈ ការរំលាយសមាគម ការធ្វើសម្ព័ន្ធភាព និងការផ្ទេរទ្រព្យសម្បត្តិនៅពេលសមាគមត្រូវរំលាយ ។

៦- លក្ខន្តិកៈរបស់សមាគម ត្រូវចុះហត្ថលេខាដោយតំណាងស្ថាបនិក ឬប្រធាន ។

### មាត្រា ១៦ ឃ្លាទី ២:

ការរំលាយសមាគមមួយ អាចបណ្ដាលមកពី:

- ការសំរេចរំលាយដោយខ្លួនឯង ។
- ការសំរេចរំលាយដោយរដ្ឋបាល ។
- ការសំរេចរំលាយដោយតុលាការ ។

.....

២- ការរំលាយដោយរដ្ឋបាល គឺជាការបញ្ឈប់សកម្មភាពរបស់សមាគម ដែលធ្វើឡើងដោយប្រកាស និង តាមការផ្តួចផ្តើមរបស់ក្រសួងមហាផ្ទៃ ក្នុងករណីដែលសមាគម បានប្រព្រឹត្តសកម្មភាពរំលោភច្បាប់ បណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិ ឬប្រពៃណីល្អរបស់សង្គមខ្មែរ ឬ រំលោភលើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សមាគម ។ ក្រសួងមហាផ្ទៃ ត្រូវផ្ញើឯកសារ និងភស្តុតាង នៃសកម្មភាពល្មើសរបស់សមាគមទៅតុលាការ ។ ការរំលាយដោយរដ្ឋបាលនេះ សមាគម អាចប្តឹងតវ៉ាទៅតុលាការក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលសេចក្តីប្រកាសរបស់ក្រសួងមហាផ្ទៃ ។ បើសិនលើសពីរយៈពេលប្តឹងនេះ ប្រកាសរបស់ក្រសួងមហាផ្ទៃ មានប្រសិទ្ធិភាពអនុវត្ត ។

.....

### មាត្រា ២៩:

បទបញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

## ពង្រាងច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

### មាត្រា ៣ កថាខ័ណ្ឌទី ៦:

វាក្យសព្ទ ដូចចែងក្នុងច្បាប់នេះ មាននិយមន័យដូចខាងក្រោមៈ

- .....
- .....
- .....
- កងកំលាំងឯកសណ្ឋាន សំដៅដល់កងកំលាំងនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដោយរាប់បញ្ចូលទាំងកងរាជអាវុធហត្ថ ។
- មន្ត្រី សំដៅដល់អ្នករាជការ ក្នុងក្របខ័ណ្ឌមុខងារសាធារណៈទាំងឡាយ និងមន្ត្រីតុលាការ មន្ត្រីនៃស្ថាប័នកំពូលនានា ។
- ជនស៊ីវិល សំដៅដល់ជនទាំងឡាយដែលមិនស្ថិតនៅក្នុងវាក្យខ័ណ្ឌទី ៤ និងទី៥ ។

### មាត្រា ៤:

ត្រូវហាមឃាត់ ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការជួល ការផលិត ការច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ចំពោះជនស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦:**

អាចត្រូវបានអនុញ្ញាតចំពោះជនស៊ីវិលៈ
- កាំភ្លើង និគ្រាប់បាញ់កំណត់សញ្ញា ឬកាំភ្លើង និងគ្រាប់បាញ់សំរាប់សកម្មភាពកីឡា
- កាំភ្លើងដែលបាញ់ មិនមានបញ្ចូនក្បាលគ្រាប់ ឬគ្រាប់ប្រាយ ដូចជា កាំភ្លើងបាញ់បញ្ចូនកាំជ្រួចលំអ ឬកាំភ្លើងគ្រាន់តែផ្ទុះស្នូរគ្មានក្បាលគ្រាប់សំរាប់សំដែងសិល្បៈ ។
- គ្រឿងផ្ទុះសំរាប់សេវាកម្មសាធារណៈ និងវិស្វករស៊ីវិល ឬសំរាប់ផ្ទុះលំអ ។

លក្ខខណ្ឌ និងនីតិវិធី សំរាប់អនុវត្តបទប្បញ្ញត្តិនេះ ត្រូវកំណត់ដោយអនុក្រិត្យតាមសំណើរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៨ កថាខ័ណ្ឌទី ២:**

.....

តាមសំណើសុំជាផ្លូវការ រាជរដ្ឋាភិបាល អាចផ្តល់ការលើកលែងចំពោះអង្គរក្សបរទេស ជាអាទិ៍មានព្រះមហាក្សត្រ ឬព្រះមហាក្សត្រយានីប្រធានាធិបតី ប្រមុខរដ្ឋ នាយករដ្ឋមន្ត្រី ឥស្សរជនជាន់ខ្ពស់ ដែលយាង ឬអញ្ជើញមកធ្វើទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៩:**

ការចុះបញ្ជីគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថ-កិច្ចរបស់ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។

**មាត្រា ១១ កថាខ័ណ្ឌទី ៤:**

.....

ប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់អាវុធរបស់អង្គភាព ត្រូវបានបញ្ជាក់បន្ថែមអំពីកាតព្វកិច្ចតំរូវឱ្យយកអាវុធមករក្សាទុកក្នុងឃ្លាំងវិញ ។

.....

**មាត្រា ១៣:**

ដើម្បីធានាសុវត្ថិភាពសាធារណៈ និងដើម្បីបង្កាទប់ស្កាត់គ្រោះមហន្តរាយដល់អាយុជីវិត ឬទ្រព្យសម្បត្តិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ អាចបញ្ជាឱ្យជន្លៀសប្រជាជនចេញពីលំនៅដ្ឋានជាបណ្តោះអាសន្ន ក្នុងករណី ដឹងថាតមបន់ឃ្លាំងស្តុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនោះ អាចមានការផ្ទុះឡើង

បែបបទនៃការអនុវត្តន៍ ត្រូវកំណត់ដោយអនុក្រិត្យ ។

**មាត្រា ២០:**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តផ្ទុយនឹងមាត្រា ៨ និង ១៤ នៃច្បាប់នេះ ។

## សេចក្តីព្រាងច្បាប់ជលផល

### មាត្រា ៤:

ដែននេសាទ មាន:

១- ដែននេសាទទឹកសាប: ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក នាទីព្រៃលិចទឹក ឬប្រឡាយ ត្រពាំង រណ្តៅ ដែលមានប្រភពទឹកពីទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង ។

២- ដែននេសាទសមុទ្រ: ផ្ទៃលាតសន្ធឹងពីខ្សែបន្ទាត់ដែលទឹកជោរខ្ពស់ រហូតដល់ព្រំប្រទល់សមុទ្រខាងក្រៅ ដែលបានប្រកាសដោយព្រះរាជាណាចក្រកម្ពុជា និងនាទីព្រៃលិចទឹក ។

ដែននេសាទ គឺជាកម្មសិទ្ធិរបស់រដ្ឋ ។

### មាត្រា ៥:

ដែននេសាទទឹកសាបចែកជា:

ក. ដែននេសាទរៀបដោយពួក:

១-កន្លែងនេសាទដែនត្រូវកំណត់ជាឡូត៍នេសាទ ហើយដែលបំរុងទុកសមរាប់តែជួលឱ្យធ្វើអាជីវកម្មនេសាទ ជាលក្ខណ:ឧស្សាហកម្ម ។

២-កន្លែងនេសាទបំរុងទុក ជាជំរករក្សាពូជវារីសត្វ និងវារីរុក្ខជាតិ

៣- នាទីព្រៃលិចទឹកគឺ:

- តំបន់ព្រៃទាំងអស់ដែលលិចទឹកនៅរដូវទឹកឡើង និងដែលជាជំរកចាំបាច់របស់វារីសត្វក្នុងការស្វែង រកចំណី និងកន្លែងពងកូន
- តំបន់លិចទឹកដែលត្រូវការពារ

៤- កន្លែងនេសាទគ្រួសារជាកន្លែងនេសាទដែលរក្សាទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទជាលក្ខណ:គ្រួសារ ។

ខ. ដែននេសាទដែលត្រូវការពារ គឺជាកន្លែងនេសាទទាំងឡាយ ដែលពុំមានចែងក្នុងប្រភេទណាមួយនៃដែននេសាទរៀបដោយពួកដែលចែងក្នុងចំណុច "ក" នៃមាត្រានេះ ។

### មាត្រា ១៥:

ការធ្វើនេសាទជាលក្ខណ:គ្រួសារ គឺគ្រាន់តែសំរាប់ផ្គត់ផ្គង់ផលនេសាទ និងគាំទ្រដល់គ្រួសារប៉ុណ្ណោះ ហើយអាចប្រព្រឹត្តទៅបានគ្រប់ពេលវេលានៅក្នុងដែននេសាទដែលត្រូវការពារ ក្នុងកន្លែងនេសាទគ្រួសារក្នុងរដូវបិទនេសាទនៅក្នុងឡូត៍នេសាទនៃដែននេសាទទឹកសាប ឬនៅក្នុងដែននេសាទសមុទ្រដោយប្រើឧបករណ៍នេសាទគ្រួសារ ។

### មាត្រា ៩៣:

ក. រដ្ឋបាលនេសាទ មានសិទ្ធិសំរេចពីការពិន័យលើបទល្មើសនេសាទ និងការកំណត់ឱ្យសងការខូចខាត ដើម្បីរួចផុតពីការចោទប្រកាន់របស់តុលាការ ។ រយៈពេលបង់ប្រាក់ពិន័យ មិនឱ្យលើសពី ៣០ថ្ងៃ ក្រោយពីថ្ងៃចេញសេចក្តីសំរេចពិន័យ ។
ខ. គំរូលិខិតនៃការបង់ពិន័យ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ៣) បទបញ្ញត្តិផ្សេងៗ

### បទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី

### មាត្រា ២: ការរៀបចំ មហាសន្និបាតគណៈមេធាវី

មហាសន្និបាត ប្រមូលផ្តុំមេធាវីទាំងអស់ដែលត្រូវបានចុះឈ្មោះ ក្នុងបញ្ជីគណៈមេធាវី និងចុះឈ្មោះក្នុងបញ្ជីមេធាវីកម្មសិក្សា ។

មហាសន្និបាតនេះ មានគោលដៅ ជូនព័ត៌មាន ឬពិគ្រោះយោបល់ ។ មហាសន្និបាត អាចលើកសំណូមពរ ឬលើកញ្ញត្តិ ដែលក្រុមប្រឹក្សាគណៈមេធាវី ត្រូវសំរេចក្នុងចិរៈវេលា ៣ខែ ។

មានតែមេធាវីដែលមានសិទ្ធិបោះឆ្នោត ទើបអាចចូលរួមក្នុងការពិភាក្សារបស់មហាសន្និបាត ។

ក្រៅពីការកោះប្រជុំសំរាប់ធ្វើការបោះឆ្នោត ការកោះប្រជុំមហាសន្និបាត ត្រូវធ្វើយ៉ាងហោចណាស់មួយឆ្នាំម្តង តាមការសំរេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ដែលជាអ្នករៀបចំរបៀបវារៈ ។

លើកលែងតែមានកិច្ចការប្រញាប់ របៀបវារៈនេះ ត្រូវឱ្យសហភាតាបានដឹងមួយខែមុនយ៉ាងតិចតាមគ្រប់មធ្យោបាយសមស្រប ។

មេធាវីមួយរូបៗ អាចសុំចុះបញ្ហារបស់ខ្លួនក្នុងរបៀបវារៈបាន ដោយធ្វើពាក្យសុំផ្ញើទៅក្រុមប្រឹក្សាគណៈមេធាវី ១៥ថ្ងៃ យ៉ាងតិចមុនថ្ងៃប្រជុំ តាមរយៈនៃលិខិតអនុសិដ្ឋ ដែលមានចុះថាបានទទួល ឬតាមលិខិត ដាក់ជូនអគ្គលេខាធិការដ្ឋាន ដោយមានបង្កាន់ដៃទទួល ។

មហាសន្និបាត ប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានគណៈមេធាវី ។

បើប្រសិនជាត្រូវធ្វើការបោះឆ្នោត ត្រូវធ្វើឡើងដោយការលើកដៃ លើកលែងតែក្នុងករណីជ្រើសរើសប្រធានគណៈមេធាវី និងសមាជិកនៃក្រុមប្រឹក្សាគណៈមេធាវី ។

ការបោះឆ្នោតតាមព្រឹតបត្តិសំងាត់ អាចសំរេចដោយប្រធានគណៈមេធាវី ឬដោយសំណើរបស់សមាជិកដែលមានចំនួន១/៤ នៃសមាជិកអវត្តមាន ។

### មាត្រា ៣: ការរៀបចំការបោះឆ្នោត

ការបោះឆ្នោតជ្រើសរើសមាជិក ក្រុមប្រឹក្សាគណៈមេធាវី ត្រូវធ្វើឡើង ៣ឆ្នាំម្តង ។ ការបោះឆ្នោតជ្រើសរើសប្រធានគណៈមេធាវី ត្រូវធ្វើឡើង ២ឆ្នាំម្តង ។

ការបោះឆ្នោតប្រព្រឹត្តទៅនៅថ្ងៃទី ១៦ ខែតុលា នៃឆ្នាំដែលត្រូវបោះឆ្នោតក្នុងសម័យប្រជុំជាសាធារណៈ ។

មេធាវីអ្នកបោះឆ្នោត ត្រូវកោះអញ្ជើញ មួយខែ មុនថ្ងៃបោះឆ្នោត តាមគ្រប់មធ្យោបាយសមស្រប (លិខិតមានលក្ខណៈជាសារាចរ ឬផ្សាយតាមវិទ្យុ ទូរទស្សន៍ សារព័ត៌មាន និងប្រកាសបិទផ្សាយនៅបន្ទីរគណៈ-មេធាវី) ។

បេក្ខភាព ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដាក់ជូនទៅប្រធានគណៈមេធាវី យ៉ាងតិច ១ខែមុនការបោះឆ្នោត បើមិនដូច្នោះ និងមិនត្រូវបានទទួលឡើយ ។ ឈ្មោះនៃបេក្ខជនទាំងអស់ ត្រូវផ្សព្វផ្សាយតាមគ្រប់វិធីសមស្របហើយត្រូវបិទនៅការិយាល័យបោះឆ្នោត ។

ការបោះឆ្នោត និងអាចប្រព្រឹត្តទៅ លុះត្រាវត្តមានសមាជិកនៃគណៈមេធាវី មានចំនួនលើសពីពាក់កណ្តាល ។

ការិយាល័យបោះឆ្នោត ត្រូវស្ថិតនៅក្រោមអធិបតីភាព របស់មេធាវីដែលមានវ័យចំណាស់ជាងគេ ។

ប្រធានគណៈមេធាវី ឬតំណាងប្រធានគណៈមេធាវី អារកាត់លើគ្រប់ឧបសគ្គ ដែលអាចកើតមាននៅពេលបោះឆ្នោត ឬនៅពេលរាប់សន្លឹកឆ្នោត ។

មេធាវី នៅពេលចូលទៅកាន់ការិយាល័យបោះឆ្នោត ត្រូវបង្ហាញប័ណ្ណវិជ្ជាជីវៈ ដើម្បីបញ្ជាក់ពីគុណសម្បត្តិនៃអ្នកមានសិទ្ធិបោះឆ្នោត ។

ការបោះឆ្នោត តាមរយៈការប្រគល់សិទ្ធិ អាចទទួលយកបាន ។ មេធាវីម្នាក់ៗ អាចទទួលការប្រគល់សិទ្ធិបានតែមួយប៉ុណ្ណោះ ។

គ្រប់ការបោះឆ្នោតណាដែលដៅទៅលើជនដែលគ្មានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យ ត្រូវចាត់ទុកជាមោឃៈ ។ ការបោះឆ្នោតដោយក្រដាស សលាត ឬមោឃៈ ត្រូវរាប់ទុកដោយឡែក និងមិនត្រូវបានលើកយកមករាប់បញ្ចូល ដើម្បីគិតរកភាគច្រើនឡើយ ។

លទ្ធផលនៃការបោះឆ្នោត ត្រូវប្រកាសដោយប្រធានគណៈមេធាវី បន្ទាប់ពីការរាប់សន្លឹកឆ្នោត ហើយលទ្ធផលនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅលោកអគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍ ។ ក្រុមប្រឹក្សាគណៈមេធាវី ត្រូវទទួលដឹងឮលទ្ធផលនេះ នៅសម័យប្រជុំរបស់ខ្លួនជាបន្ទាប់ ។

## បទបញ្ជាផ្ទៃក្នុងរដ្ឋសភា

### ប្រការ ៥:

អ្នកតំណាងរាស្ត្រមានឋានៈ និងបុព្វសិទ្ធិ ស្មើនឹងឧត្តមមន្ត្រីផុតលេខ នៃ ព្រះរាជាណាចក្រកម្ពុជា ។

### ប្រការ ៦:

ក្រោមអធិបតីភាពនៃប្រធានរដ្ឋសភា រដ្ឋសភាដំណើរការបោះឆ្នោតជ្រើសតាំងសមាជិក នៃគណៈកម្មការនានារបស់រដ្ឋសភា ។

គណៈកម្មការនានានៃរដ្ឋសភាមានៈ

១- គណៈកម្មការ ការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង

២- គណៈកម្មការ ហិរញ្ញវត្ថុ និងធនាគារ

៣- គណៈកម្មការ សេដ្ឋកិច្ច ផែនការវិនិយោគ ពាណិជ្ជកម្ម កសិកម្ម អភិវឌ្ឍន៍ជនបទ និង បរិដ្ឋាន
៤- គណៈកម្មការ មហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាត
៥- គណៈកម្មការកិច្ចការ បរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
៦- គណៈកម្មការ នីតិកម្ម
៧- គណៈកម្មការ អប់រំ ធម្មការ វប្បធម៌ និងទេសចរណ៍
៨- គណៈកម្មការ សុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី
៩- គណៈកម្មការ សាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម និងថាមពល ។

**ប្រការ ៩:**

អនុប្រធានរដ្ឋសភា ២រូប ជាអ្នកជួយការងារដល់ប្រធានរដ្ឋសភា ។ នៅពេលដែលប្រធានរដ្ឋសភាអវត្តមាន ឬខកខានមិនបានមកធ្វើការ អនុប្រធានរដ្ឋសភា បំពេញមុខងារជំនួសប្រធានរដ្ឋសភា ។

**ប្រការ ២១:**

សេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល ត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។ សេចក្តីព្រាងច្បាប់នោះ ជាលិខិតលាយលក្ខណ៍អក្សរ ហើយត្រូវចែកជូនអ្នកតំណាងរាស្ត្រទាំងអស់ ព្រមទាំងសេចក្តីថ្លែងហេតុមកជាមួយផង ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បញ្ជូនសេចក្តីនោះ ទៅគណៈកម្មការតាមមុខជំនាញឱ្យពិនិត្យ ។ កាលបើពិនិត្យរួចហើយ ប្រធាននៃគណៈកម្មការនោះ ត្រូវនាំយកយោបល់របស់គណៈកម្មការ មកជំរាបជូនរដ្ឋសភា ។

**ប្រការ ២២:**

សេចក្តីស្នើច្បាប់ ដែលអ្នកតំណាងរាស្ត្រជាអ្នកធ្វើនោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចែកជាមាត្រា ហើយមានសេចក្តីថ្លែងហេតុនៅខាងដើមជាប់មកផង ។

**ប្រការ ២៤:**

គណៈកម្មការ អាចសន្និដ្ឋានថា:

- សូមឱ្យរដ្ឋសភា លើកចោលពុំពិចារណាក៏បាន ។
- សូមឱ្យរដ្ឋសភា បញ្ចេញមតិជាមុនសិន តើគួរទទួលពិចារណា ឬទេ ។
- សូមឱ្យរដ្ឋសភា ទទួលពិចារណាហើយ នឹងទុកជាការប្រញាប់ផង ក៏បាន ។

**ប្រការ ២៧:**

អង្គសភាសំរេចថា យល់ព្រម ឬមិនយល់ព្រម យកពាក្យសុំនោះមកពិភាក្សា ។

**ប្រការ ២៨:**

អង្គសភា មិនអនុម័តលើវិសោធនកម្មក្នុងថ្ងៃដែលទទួលពាក្យសុំនោះទេ វៀរលែងតែជាការប្រញាប់ ។

**ប្រការ ២៩:**

ការពិភាក្សាលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ត្រូវធ្វើដូចតទៅ:

១- អង្គសភាពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូលគឺបញ្ចេញមតិថា តើគួរទទួលពិចារណាឬទេ ។

២- អង្គសភាពិភាក្សា និងអនុម័តលើមាត្រាមួយម្ដង១ក៏បាន ឬលើជំពូកមួយម្ដង១ក៏បាន ។

អង្គសភា អាចប្រើនីតិវិធីពិភាក្សាសង្ខេបបាន ដោយពិភាក្សាតែមាត្រា ឬជំពូកណាដែលមានសំណើធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ ។

ក្នុងករណីដែលនឹងត្រូវប្រើនីតិវិធីណាមួយខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវជូនព័ត៌មានដល់អ្នកតំណាងរាស្ត្រជាមុន ។

៣-អង្គសភាអនុម័តលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ទាំងមូល ។

**ប្រការ ៣២:**

អ្នកតំណាងរាស្ត្រ មានសិទ្ធិដាក់សំនួរដល់រាជរដ្ឋាភិបាល ។ សំនួរនេះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។

ចំលើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប ។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។

ចំលើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីអាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយល័ក្ខណ៍អក្សរ ។

ចំលើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំនួរ ។

ចំពោះចំលើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសំរេចបើកឱ្យមាន ឬមិនឱ្យមានការជជែកដេញដោល ។ បើគ្មានការបើកឱ្យជជែកចេញដោលទេ នោះចំលើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី នឹងបញ្ចប់សំនួរតែម្ដង ។

**ប្រការ ៣៣:**

អ្នកតំណាងរាស្ត្រ ដែលបានតាំងសំណួរចំពោះរដ្ឋមន្ត្រីណាមួយ អាចសុំដកលិខិតតាំងសំណួររបស់ខ្លួនចេញបាន ។

អ្នកតំណាងរាស្ត្រឯទៀត អាចទទួលយកពាក្យសុំតាំងសំណួរដែលដកចេញហើយនោះ ទៅជូនប្រធានរដ្ឋសភាសាជាថ្មីទៀតបាន កាលបើយល់ឃើញថាចាំបាច់ ។

បើមានការបើកអោយជជែកដេញដោលម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធ ឬនាយករដ្ឋមន្ត្រីអាចជជែកប្ដូរយោបល់ក្នុងរយៈពេល ដែលមិនអាចលើសពីមួយពេលប្រជុំឡើយ ។

រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃ ក្នុងមួយសប្ដាហ៍ សំរាប់ការឆ្លើយសំណួរ ។

ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសំរាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ ។

**ប្រការ ៣៤:**

គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រី ឬវរជនណាមួយមកបំភ្លឺអំពីបញ្ហាអ្វីមួយ ដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន។

**ប្រការ ៣៥:**

រដ្ឋសភា អាចទំលាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទំលាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញត្តិបន្ទោស តាមសំលេងឆ្នោតភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ យ៉ាងតិច ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

**ប្រកា ៣៧:**

ចំពោះការបញ្ចេញមតិដោយវិធីលើកដៃ ប្រធាន និងលេខាធិការទាំងឡាយ ជាអ្នករាប់ចំនួនសមាជិក ដែលលើកដៃ ។ បើប្រធាន និងលេខាធិការទាំងនោះឃើញថា ការបញ្ចេញមតិ មិនបានលទ្ធផលច្បាស់លាស់ទេ នោះត្រូវបញ្ចេញមតិ និងរាប់សាជាថ្មីទៀត ។

**ប្រការ ៣៨:**

កាលបើការបញ្ចេញមតិដោយវិធីលើកដៃ បានធ្វើពីរដងហើយនៅតែមិនទាន់បានលទ្ធផលច្បាស់លាស់ ទេនោះ ត្រូវប្រើវិធីបោះឆ្នោតជាចំហ ។

វិធីបោះឆ្នោតចំហនេះ ត្រូវធ្វើដូចតទៅ:

អាជ្ញាសភាកាន់ហិបឆ្នោត ដើរទទួលប្រមូលយកសន្លឹកឆ្នោតពីសមាជិករដ្ឋសភា ។ សមាជិករដ្ឋសភា ត្រូវសរសេរឈ្មោះខ្លួនលើសន្លឹកឆ្នោតនោះ ។ សន្លឹកឆ្នោតមាន បីយ៉ាង: ពណ៌ខៀវសំគាល់ថាមិនព្រម ពណ៌ស សំគាល់ថាព្រម និងពណ៌សឆ្នូតខៀវ សំគាល់ថាអនុប្បវាទ ។

ក្រោយពីបោះឆ្នោតរួចស្រេចហើយ លេខាធិការរាប់សន្លឹកឆ្នោត ។ ដល់រាប់សន្លឹកឆ្នោតរួចហើយ ប្រធាន រដ្ឋសភា ត្រូវប្រកាសលទ្ធផលជូនអង្គសភាស្តាប់ ។

**ប្រការ ៣៩:**

វិធីបោះឆ្នោតចំហនៅវេទិកា ប្រព្រឹត្តទៅដូចតទៅនេះ:

អ្នកតំណាងរាស្ត្រម្នាក់ៗ ដើរយកសន្លឹកឆ្នោតមកបោះក្នុងហិប ដែលដាក់នៅលើវេទិកា ។

វិធីនេះនឹងយកមកប្រើបាន លុះត្រាតែមានអ្នកតំណាងរាស្ត្រ ១០នាក់ យ៉ាងតិចស្នើសុំ ។

**ប្រការ ៤០:**

វិធីបោះឆ្នោតសំងាត់ ត្រូវតែប្រើក្នុងការជ្រើសតាំង ការសំដែងការទុកចិត្ត និងការអនុម័តញត្តិបន្ទោស ។ ការអនុម័តច្បាប់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ អាចប្រព្រឹត្តដោយវិធីបោះឆ្នោតសំងាត់ដែរ ។

**ប្រការ ៥៩:**

តាមធម្មតា អ្នកតំណាងរាស្ត្រដែលបានចុះឈ្មោះសុំនិយាយ និយាយបាន ២០នាទី យ៉ាងយូរ ។ អ្នកតំណាងរាស្ត្រដែលគ្រាន់តែសុំឆ្លើយតប និយាយបានតែ ៥នាទីទេ ។

បើប្រធានយល់ឃើញថាជាការចាំបាច់ ឬជាការមានប្រយោជន៍ក្នុងការពិភាក្សានោះ ប្រធាន អាចអនុញ្ញាតបន្ថែមពេលឱ្យនិយាយ ១០នាទី ទៀតបាន ។ ការបន្ថែមនេះ អាចអនុញ្ញាតឱ្យបន្តបាន ៣ដងក្នុងរឿងដដែល ។

**ប្រការ ៦២:**

ហាមមិនឱ្យនិយាយកាត់ពាក្យអ្នកដទៃ មិនឱ្យនិយាយវាយប្រហារលើបុគ្គល មិនឱ្យសំដែងអាការៈផ្សេងៗ ដែលនាំឱ្យខូចសណ្តាប់ធ្នាប់ ។

**ប្រការ ៦៤:**

ការថែរក្សាការពារសេចក្តីសុខសាន្តរបស់រដ្ឋសភា ត្រូវធ្វើឡើងដោយប្រធានរដ្ឋសភា ក្នុងនាមរដ្ឋសភា ។ ជាគោលការណ៍ ប្រធានរដ្ឋសភា អនុញ្ញាតឱ្យសាធារណជនចូលក្នុងសាលប្រជុំបានតាមចំនួនកន្លែងដែលមាន ។ ប៉ុន្តែបើជនណាធ្វើឱ្យរង្អៀសតាមវិធីណាក្តីដល់ការពិភាក្សារបស់អង្គសភា ប្រធានអាចបញ្ជាឱ្យបណ្តេញចេញភ្លាម ។

**ប្រការ ៦៨:**

ប្រធាន អាចអនុញ្ញាតឱ្យសមាជិករដ្ឋសភាឈប់បានយ៉ាងយូរ រួមទាំងអស់ ១៥ថ្ងៃ ក្នុងសម័យប្រជុំនីមួយៗ ។ ការឈប់លើសពី ១៥ថ្ងៃ ត្រូវសុំឱ្យអង្គសភាអនុម័តយល់ព្រម ។

**ប្រការ ៦៩:**

អ្នកតំណាងរាស្ត្ររូបណា ដែលអវត្តមានដោយមូលហេតុមានជំងឺរយៈពេល ៥ថ្ងៃ ជាប់ៗគ្នា ត្រូវមានសំបុត្រពេទ្យយកមកជាសំអាង ។

**ប្រការ ៧០:**

តំណាងរាស្ត្រណាឈប់ខានមកប្រជុំលើសពីបីថ្ងៃ ដោយគ្មានការអនុញ្ញាត ត្រូវកាត់ប្រាក់បំណាច់រដ្ឋសភាចំពោះថ្ងៃដែលអវត្តមាននោះ ។

**ប្រការ ៧១:**

អ្នកតំណាងរាស្ត្ររូបណា បានទទួលការអនុញ្ញាតឱ្យឈប់ ហើយឈប់លើសចំនួនថ្ងៃអនុញ្ញាតនោះ ត្រូវកាត់ប្រាក់បំណាច់ ចំពោះថ្ងៃដែលឈប់លើសពីការអនុញ្ញាត ។

## ប្រការ ៧២:

កាលបើមានសេចក្តីអញ្ជើញមកប្រជុំតាមបទបញ្ញត្តិនៃប្រការ៤៩ ហើយអ្នកតំណាងរាស្ត្រ មិនបានមកប្រជុំ ដោយឥតមានមូលហេតុយកជាការបាន អ្នកតំណាងរាស្ត្រនោះ ត្រូវទទួលទណ្ឌកម្មខាងវិន័យ ដូចខាងក្រោមនេះ:

ក- ការខានមកប្រជុំលើសពី ២ថ្ងៃ ត្រូវព្រមាន

ខ- បើបានទទួលការព្រមានដល់ទីលំនៅហើយ ហើយនៅតែមិនចូលមកប្រជុំ នោះត្រូវកាត់ប្រាក់បំណាច់ រដ្ឋសភាតាមចំនួនថ្ងៃអវត្តមាន ។ ទណ្ឌកម្មខាងវិន័យនេះ ត្រូវប្រគល់ដល់ទីលំនៅរបស់សាមីខ្លួន ។

គ- បើបានទទួលដំណឹងលើកក្រោយនេះហើយ ហើយនៅតែមិនចូលមកប្រជុំ ឬមិនផ្តល់សេចក្តីដោះសារ ដោយមានមូលហេតុយកជាការបាន នោះត្រូវដាក់ទណ្ឌកម្មខាងវិន័យទី៣ គឺកាត់ប្រាក់បំណាច់រដ្ឋសភា តាមចំនួនថ្ងៃអវត្តមាន ហើយថែមទាំងបណ្តេញចេញពីការប្រជុំចំនួន ១៥ថ្ងៃ ។

បើបានទទួលទណ្ឌកម្មខាងវិន័យទាំង ៣ យ៉ាងខាងលើនេះហើយ ហើយក្នុងរវាងមួយខែក្រោយមក អ្នកតំណាងរាស្ត្រដដែលនៅតែប្រព្រឹត្តខុសទៀត ត្រូវធ្វើទណ្ឌកម្មខាងវិន័យជាទំងន់ ដោយកាត់ប្រាក់បំណាច់តាមចំនួនថ្ងៃដែលអវត្តមាន និងបណ្តេញពីការប្រជុំរយៈពេលមួយខែ ប្រកាសផ្សាយដល់មហាជននៅក្នុងមណ្ឌលនៃអ្នកតំណាងរាស្ត្រដែលបានប្រព្រឹត្តខុស ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ជាអ្នកដាក់ទណ្ឌកម្មខាងវិន័យ ដោយស្វ័យប្រវត្តិ កាលបើបានដឹងច្បាស់ថា ហេតុដែលខានមកប្រជុំនោះមិនអាចយកជាការបាន វៀរលែងតែករណីដែលរដ្ឋសភា បានទទួលពាក្យតវ៉ាសមហេតុផល អំពីសាមីខ្លួនក្នុងពេលប្រជុំពេញអង្គ ។